# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 1234

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ផ្នែក ក

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : វាយតម្លៃភាពសំបូរបែប និងបរិមាណកូនត្រីនៅតាមដៃនៃបឹងទន្លេសាប

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្ដើមគម្រោង 04/04/24

កាលបរិច្ឆេទបញ្ចប់គម្រោង 31/03/26

៣. ចំណាយគម្រោងសរុប $270,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT FiA

អង្គភាពទទួលខុសត្រូវ រដ្ឋបាលជលផល

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងចូលរួមចំណែកដល់ការរៀបចំផែនការ និងគ្រប់គ្រងធនធានជលផលនៅក្នុងបឹងទន្លេសាប និងដៃរបស់វា ក៏ដូចជាចូលរួមផ្ដល់ព័ត៌មានអំពីផលប៉ះពាល់ពីការអភិវឌ្ឍនានាតាមដៃបឹងទន្លេសាប។

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

Fisheries

Fisheries

Fisheries

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

បន្ទាយមានជ័យ, ពោធិ៍សាត់, កំពង់ឆ្នាំង, បាត់ដំបង, សៀមរាប, កំពង់ធំ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- វាយតម្លៃស្ថានភាពនៃភាពសំបូរបែប និង បរិមាណនៃកូនត្រីដែលចូលទៅក្នុងបឹងទន្លេសាប
- បង្កើតមូលដ្ឋានទិន្នន័យ និងផ្តល់ព័ត៌មានស្តីពីផលប៉ះពាល់ធនធានជលផលពីការអភិវឌ្ឍនានានៅតាមដៃបឹងទន្លេសាបដល់រាជរដ្ឋាភិបាលក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗទៀត
- ផ្តល់វិធានការជាជម្រើសផ្សេងៗសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការរៀបចំផែនការ និងការគ្រប់គ្រងធនធានជលផលនៅតាមដៃនានានៃបឹងទន្លេសាប។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះនឹងត្រូវអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល។ ដៃទន្លេសំខាន់ចំនួនមួយនៅក្នុងខេត្តនីមួយនឹងត្រូវជ្រើសរើសដើម្បីធ្វើការសិក្សា តាមដាន និងវាយតម្លៃ ចាប់ពីខែឧសភា ដល់ខែកញ្ញា រៀងរាល់ឆ្នាំ។ សំណាកកូនត្រីដែលចាប់បានពីដៃទន្លេនីមួយៗត្រូវនាំយកមករក្សាទុកក្នុងមន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប ដើម្បីធ្វើការកំណត់អត្តសញ្ញាណកូនត្រី និងសិក្សាបន្ថែមអំពីលក្ខណៈជីវសាស្ត្ររបស់ប្រភេទកូនត្រីនីមួយៗ។ ស្ថានភាពដៃទន្លេ ដូចជារុក្ខជាតិទឹកទទឹងទន្លេ ជម្រៅទឹក ល្បឿនទឹកហូរ និង គុណភាពទឹកនឹងត្រូវកត់ត្រា និងធ្វើការវិភាគ។ ម្យ៉ាងទៀត ទិន្នន័យបន្ទាប់បន្សំដែលពាក់ព័ន្ធមាននៅក្នុងឯកសារការសិក្សាស្រាវជ្រាវកន្លងមក និងស្ថាប័នជំនាញផ្សេងៗទៀតនឹងត្រូវធ្វើការប្រមូលផងដែរ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ដៃសំខាន់ៗនៃបឹងទន្លេសាប គឺផ្លូវមួយយ៉ាងសំខាន់របស់ត្រីក្នុងការធ្វើចរាចរណ៍ឡើងចុះ ដើម្បីពងកូន ដើម្បីរកចំណី និងរីកធំធាត់។ ការដឹងច្បាស់ពីប្រភេទកូនត្រី បរិមាណត្រីដែលឆ្លងកាត់ការកាត់ ស្ថានភាពទីជម្រកនៅតាមដងទន្លេ របបទឹក គុណភាពទឹក ជម្រៅទឹក និងល្បឿនលំហូរទឹកតាមដៃទន្លេ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាផល ស្តុកត្រីឱ្យបានគង់វង់សម្រាប់បរិភោគ អាហាររូបត្ថម្ភ និងបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។ លើសពីនេះការសសិក្សា ស្រាវជ្រាវនេះ នឹងបង្កើតបានជាមូលដ្ឋានទិន្នន័យមួយច្បាស់លាស់ក្នុងការរៀបចុះផែនការគ្រប់ គ្រង និងអភិរក្សធន ធានជលផលប្រកបដោយចីរភាព។ ការដែលពុំបានដឹងច្បាស់ចំណុចសំខាន់ៗដូចបានរៀបរាប់ខាងលើនោះទេ នោះការធ្វើផែនការគ្រប់គ្រងធនធានជលផលដើម្បីរក្សាបាននូវផលស្តុកធនធានជលផលនៅក្នុងធម្មជាតិនឹងមិនអាចសម្រេចបានឡើយ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកនេសាទ និងគ្រួសាររបស់ពួកគេ ប្រជាជននៅមូលដ្ឋាន មន្ត្រីជលផល និងអាជ្ញាធរមូលដ្ឋាន

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**មិនមានផលប៉ះពាល់ណាមួយរបស់គម្រោងលើប្រជាជន និងបរិស្ថានជុះវិញតំបន់អនុវត្តគម្រោងនោះទេ មិនតែប៉ុណ្ណោះ គម្រោងបានរួមចំណែកដល់សន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍប្រទេស។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងបានគិតគួរួចហើយលើសមភាពយ៉េនឌ័រ។ ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការចូលរួមអនុវត្តគម្រោងទៅតាមជំនាញ និងបទពិសោធន៍ដែលធ្លាប់មាន។ គោលដៅគម្រោងជំរុញឱ្យមានការចូលរួមពីស្ត្រីយ៉ាងតិច៤០%។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៃរដ្ឋបាលជលផលមានមន្ត្រីមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់លើការងារស្រាវជ្រាវបែបនេះក្នុងការអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**កន្លងមកការអនុវត្តគម្រោងប្រព្រឹត្តទៅបានល្អ ទាំងនេះដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៃរដ្ឋបាលជលផលមានមន្ត្រីដែលមានជំនាញគ្រប់គ្រាន់និងបទពិសោធន៍ការងាររួមទាំងការផ្តល់ថវិកាទាន់ពេលវេលា...ជាដើម។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ធនាគារពិភពលោក ធនាគារអភិវឌ្ឍអាស៊ី សហភាពអឺរ៉ុប និងជំនួយរបស់សហរដ្ឋអាមេរិក**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 90.0 | 90.0 | 90.0 | 270.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 10.0 | 10.0 | 10.0 | 30.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 15.0 | 15.0 | 15.0 | 45.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 65.0 | 65.0 | 65.0 | 195.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 90.0 | 90.0 | 90.0 | 270.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 10.0 | 0.0 | 0.0 | 10.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 90.0 | 90.0 | 90.0 | 270.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: